

# ការតភ្ជាប់អាជ្ញាធរ និង សង្គមស៊ីវិល

*ដោយសារតែភូមិសាស្ត្រសហគមន៍ជនជាតិដើមភាគតិចភាគច្រើនដែលរស់នៅក្នុងខេត្តមណ្ឌលគិរី មានភាពដាច់ស្រយាល និងភាពកាត់ផ្តាច់នេះបានបង្កបញ្ហាប្រឈមជាច្រើនទៅដល់សហគមន៍របស់ពួកគេក្នុងការភ្ជាប់ទំនាក់ទំនងទៅខាងក្រៅ។ សហគមន៍ជនជាតិដើមព្នងមួយក្រុមដែលមានឈ្មោះថា ឡេងណៃ គឺជាឧទាហរណ៍មួយនៅក្នុងករណីសិក្សានេះ។ ភូមិនេះធ្លាប់មានបទពិសោធន៍ក្នុងការខ្វះខាងផ្នែកទំនាក់ទំនងទៅខាងក្រៅ និងមានការលំបាកក្នុងការទទួលបាននូវសេវាសាធារណៈដូចជា ការថែទាំសុខភាព និងការរៀនសូត្រ ហើយនៅក្នុងភូមិគឺគ្មានទីផ្សារសម្រាប់ធ្វើការលក់បន្លែ មាន់ និងផលិតផលកសិកម្មផ្សេងៗទៀតនោះទេ។ នេះគឺជាបញ្ហាប្រឈម ដែលបានកើតឡើងនៅពេលដែលសហគមន៍របស់ពួកគេត្រូវបានកាត់ផ្តាច់ចេញពីសហគមន៍ដ៏ទៃទៀត ដោយសារតែគ្មានស្ពានសម្រាប់ឆ្លងកាត់អូរ។ ហេតុដូច្នេះហើយទើបអ្នកភូមិនេះបានសម្រេចចិត្តធ្វើការរួមគ្នាជាមួយនឹង អាជ្ញាធរមូលដ្ឋាន ចាស់ទុំក្នុងភូមិ និងគម្រោងអាយស៊ីស៊ី-អាយប៊ីស៊ីឌីអី ប្រចាំខេត្តមណ្ឌលគិរី (អប់រំ និងអភិវឌ្ឍន៍សហគមន៍ផ្អែកលើអត្តសញ្ញាណ) ដើម្បីកសាងស្ពានឈើក្នុងគោលបំណងតភ្ជាប់ភូមិរបស់ពួកគេជាមួយនឹងសង្គមខាងក្រៅ។*

មុនពេលស្ពាននេះត្រូវបានសាងសង់ឡើង នៅពេលដែលអ្នកភូមិឈឺ ឬត្រូវការប្រើប្រាស់សេវាសាធារណៈផ្សេងៗនោះ ពួកគេត្រូវដើរលុយទឹកអូរ ដើម្បីទៅត្រើយម្ខាងទៀត ឬប្រើវិធីផ្សេងទៀតដើម្បីឆ្លងកាត់ទឹកអូរនៅក្នុងអំឡុងពេលរដូវវស្សាពេលដែលទឹកអូរឡើងខ្ពស់។ បុគ្គលិកគម្រោងអាយប៊ីស៊ីឌីអី ក៏ត្រូវបានឆ្លងកាត់ឧបសគ្គទាំងអស់នេះផងដែរក្នុងការទៅជួប និងធ្វើការជាមួយប្រជាជននៅក្នុងភូមិនេះ។ លើសពីនេះទៀត ភូមិនេះត្រូវបានអង្គការក្រៅរដ្ឋាភិបាលភាគច្រើនមើលរំលង ដោយសារតែមានភាពលំបាកក្នុងការធ្វើដំណើរទៅមក។ ដោយសារតែភាពស្មុគស្មាញនេះ និងដើម្បីជម្នះបញ្ហាទាំងអស់នេះផងដែរ ប្រជាជនទាំងអស់នៅក្នុងសហគមន៍បានសម្រេចចិត្តធ្វើការជាមួយគ្នា ដើម្បីសាងសង់ស្ពានមួយនេះឡើង។ ការសាងសង់ស្ពានមួយនេះបានចាប់ផ្តើមឡើងនៅឆ្នាំ២០១៥ ហើយត្រូវបានបញ្ចប់នៅឆ្នាំ២០១៧ ដោយបានធ្វើការប្រើប្រាស់ធនធានដែលមានស្រាប់នៅក្នុងសហគមន៍ផ្ទាល់របស់ពួកគេ ក៏ដូចជាការប្រើប្រាស់មូលនិធិដែលប្រមូលបានពីប្រជាជនក្នុងសហគមន៍ អាជ្ញាធរមូលដ្ឋាន និងពីគម្រោងអាយប៊ីស៊ីឌីអីផងដែរ។

នៅពេលដែលការសាងសង់ស្ពាននេះត្រូវបានបញ្ចប់ ប្រជាជនក្នុងសហគមន៍មានភាពងាយស្រួលក្នុងការធ្វើដំណើរទៅមន្ទីរពេទ្យ ហើយពួកគេអាចលក់ផលិតផលកសិកម្មរបស់ពួកគេនៅក្នុងភូមិដទៃទៀតបានយ៉ាងងាយស្រួល។ លើសពីនេះទៀត កុមារនៅក្នុងសហគមន៍អាចធ្វើដំណើរទៅសាលារៀនបានលឿនជាងមុន និងមានសុវត្ថិភាពជាងមុនថែមទៀត ពីព្រោះពួកគេមិនចាំបាច់ត្រូវធ្វើការលុយទឹកអូរទៅសាលារៀនទៀតនោះទេ។ សេវាសាធារណៈផ្សេងៗទៀតក៏កាន់តែមានភាពងាយស្រួលដល់ប្រជាជនក្នុងសហគមន៍ផងដែរ ហើយនេះក៏ជាឱកាសអាចឲ្យអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតចាប់ផ្តើមធ្វើការងារអភិវឌ្ឍន៍នៅតាមភូមិរបស់ពួកគាត់។ អ្វីដែលសំខាន់បំផុតនោះ ការសាងសង់ស្ពានមួយនេះគឺបានប្រមូលផ្តុំប្រជាពលរដ្ឋឲ្យចូលរួមគ្នាក្នុងការអភិវឌ្ឍន៍គម្រោង ដែលការចូលរួមនេះគឺបានផ្តួចផ្តើមចេញជាអត្ថប្រយោជន៍រួមសម្រាប់សហគមន៍ទាំងមូល។ ទាំងអស់នេះហើយគឺដើរស្របតាមគោលនយោបាយ ឈ្នះ ឈ្នះ (គោលនយោបាយដែលនាំមកនូវសន្តិភាពដល់ប្រជាជនកម្ពុជា បន្ទាប់ពីសង្គ្រាមស៊ីវិលបានបញ្ចប់) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់ការធ្វើសមាហរណកម្មខាងផ្នែកសង្គម សាមគ្គីភាព និងការអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម ដែលប្រជាពលរដ្ឋកម្ពុជាម្នាក់ៗមានសិទ្ធិទទួលបានឱកាសស្មើៗគ្នា ក៏ដូចជាការទទួលបានការប្រើប្រាស់សេវាសាធារណៈដ៏ទូលំទូលាយ បូករួមជាមួយនឹងការទទួលបាននូវជីវភាពដ៏សមរម្យមួយផងដែរ។

កន្លងមក គម្រោងអាយប៊ីស៊ីឌីអី បានធ្វើការជួយដល់សហគមន៍មួយនេះទាក់ទងទៅនឹងការអប់រំក្រៅប្រព័ន្ធដូចជា ការបង្កើតប្រព័ន្ធសរសេរភាសាដើមកំណើត ក៏ដូចជាបង្រៀនពួកគេអំពីជំនាញកសិកម្ម និងជំនាញផ្សេងទៀតដែលចាំបាច់សម្រាប់ពួកគេ។ លើសពីនេះទៀត ក្រុមការងាររបស់គម្រោងអាយប៊ីស៊ីឌីអី ក៏បានធ្វើការសម្របសម្រួលទៅកាន់ប្រជាជនក្នុងសហគមន៍ក្នុងការដោះស្រាយនូវតម្រូវការ និងទុក្ខកង្វល់របស់ពួកគេ ក៏ដូចជាផ្តល់ឲ្យពួកគេនូវព័ត៌មានពីខាងក្រៅដែលមិនសូវបានជ្រាបចូលទៅដល់ក្នុងសហគមន៍របស់ពួកគេ។

កាលបរិច្ឆេទ៖ មករា ២០១៩